ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៩៣-០១៣-០៤៩ ប្រ.ក

# ប្រកាស

## ស្តីពី

## លក្ខណៈសម្គាល់នៃធនបត្រ "ព្រះបរមរតនកោដ្ឋ" ប្រភេទ ១០០០ រៀល

អនុលោមតាមអនុក្រឹត្យលេខ ៤៣ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីការចេញផ្សាយធនបត្រ "ព្រះបរមរតនកោដ្ឋ" ប្រភេទ ១០០០ រៀល ក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជាសូមប្រកាសផ្សាយជាសាធារណៈនូវលក្ខណៈសំគាល់នៃធនបត្រថ្មីនេះ មានដូចខាងក្រោម ៖

ក. លក្ខណៈទូទៅ ៖

- ទំហំធនបត្រ ៖ បណ្តោយ ១៤៥ មម និង ទទឹង ៦៨ មម
- ពណ៌ចម្បង គឺពណ៌ស៊ីជម្ពូ និងពណ៌ខៀវ ។

ខ. ផ្ទៃខាងមុខ ៖

- **ផ្នែកកណ្តាល** ខាងស្តាំត្រូវបានរំលេចឡើងនូវ ព្រះឆាយាល័ក្ខណ៍នៃព្រះបរមរតនកោដ្ឋ មើលពីមុខបញ្ឆិតចំហៀងខាងឆ្វេង និងមានចារឹកអក្សរ "**ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ (ព.ស ២៤៦៦ - ព.ស ២៥៥៦)**" នៅពីក្រោម រីឯខាងឆ្វេងមានលេខ "១០០០" នៅពីលើគេ បន្ទាប់មកគឺជាហត្ថលេខារបស់ទេសាភិបាលនិងអគ្គបេឡា ព្រមទាំងរូបភាពព្រះសង្ហារនៃព្រះរាជាណាចក្រកម្ពុជា នៅខាងក្រោមមានលេខ-មាលាបោះពុម្ពដោយទឹកខ្មៅពណ៌ខ្មៅ រូបចម្លាក់នាគក្បាល ៧ និងអក្សរ "មួយពាន់រៀល" ព្រមទាំងអក្សរ "អ្នកក្លែងក្រដាសប្រាក់នឹងត្រូវផ្តន្ទាទោសតាមច្បាប់" នៅគែមខាងក្រោមនោះ ។

- **ផ្នែកខាងស្តាំ** ជ្រុងលើមានអក្សរ "ធនាគារជាតិនៃកម្ពុជា" ព្រមទាំងលេខ-មាលាដែលត្រូវបានបោះពុម្ពដោយទឹកខ្មៅពណ៌ក្រហមនៅពីក្រោមនោះ និងជ្រុងក្រោមមានលេខ "១០០០" ព្រមទាំងលេខ "1000" នៅពីក្រោមនោះ ។

- **ផ្នែកខាងឆ្វេង** មានលេខ "1000" ដែលត្រូវបានបោះពុម្ពតាមបន្ទាត់បញ្ឈរ ព្រមទាំងរូបភាពព្រាលៗនៃក្បាច់លំអ ក្លាយពីក្បាច់អង្គរក្នុងទម្រង់ផ្កាច័នដែលមានបណ្តូលធំ ត្រូវបានបោះពុម្ពកាត់ទទឹងក្រដាសប្រាក់ និងជ្រុងក្រោមមានគំនូសបន្ទាត់ខ្លីៗជាច្រើនដែលត្រូវបានផ្គុំឡើងដោយលេខ "១០០០" ដ៏តូចល្អិត ។

គ. ផ្ទៃខាងខ្នង ៖

- **ផ្ទៃកកណ្តាល** នៃធនប័ត្រត្រូវបានរំលេចឡើងនូវរូបភាពព្រះទីនាំងសុវណ្ណហង្ស ក្នុងពិធីដង្ហែព្រះបរមសព ពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញមកដល់មុខព្រះបរមរាជវាំង ព្រមទាំងរូបភាពប្រាសាទទេវានិវិច្ឆ័យ និងមានអក្សរ "មួយពាន់រៀល" នៅពីក្រោមនោះ ។

- **ផ្ទៃកខាងស្តាំ** ជ្រុងលើមានលេខ "1000" ដែលត្រូវបានបោះពុម្ពតាមបន្ទាត់បញ្ឈរ ចំកណ្តាលមានរូបភាពក្បាច់លំអ និងនៅជ្រុងក្រោមមានលេខ "១០០០" ។

- **ផ្ទៃកខាងឆ្វេង** ជ្រុងលើមានអក្សរ **"ធនាគារជាតិនៃកម្ពុជា"** ចំកណ្តាលមានអក្សរ **"សូមថ្វាយព្រះរាជកុសល ព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ សូមទ្រង់យាងបដិសន្ធិក្នុងព្រះបរមសុគតិភព"** និងនៅជ្រុងក្រោមមានលេខ **"១000"** ព្រមទាំងលេខ **"២០១២"** ។

ចាប់ពីថ្ងៃចេញប្រកាសនេះតទៅ ធនប័ត្រ **"ព្រះបរមរតនកោដ្ឋ"** ប្រភេទ ១០០០ រៀល ត្រូវបានដាក់ឱ្យធ្វើចរាចរទន្ទឹមគ្នាជាមួយនឹងធនប័ត្រជាតិប្រភេទផ្សេងៗទៀត ដែលត្រូវបានចេញផ្សាយកន្លងមក ។ សាធារណជនគ្រប់រូបត្រូវពិនិត្យ-សម្គាល់ធនប័ត្រថ្មីនេះ ឱ្យបានច្បាស់លាស់ ដើម្បីជៀសវាងការភ័ន្តច្រឡំ ។៚

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៣

**ទេសាភិបាល**

**ជា ចាន់តូ**